**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**
ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម៖ **ខ្មែរ**
កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Jun-2020, 12:11
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ សាធារណៈ/Public
ប្រភេទនៃចំណាត់ថ្នាក់៖
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖
ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖
ហត្ថលេខា៖

---

**ចម្លើយតបរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់**

---

ដាក់ដោយ៖

**មេធាវីការពារក្តីលោក ខៀវ សំផន**
មេធាវី គង់ សំអុន
មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**
ចៅក្រម គង់ ស្រីម
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande MUMBA

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("ដើមបណ្ដឹងរដ្ឋប្បវេណី") បានដាក់ញត្តិមួយ ក្រោមចំណងជើងថា "សំណើពាក់ព័ន្ធនឹងការណ៍ដែល ខៀវ សំផន មិនអនុវត្តតាមមាត្រា ៦ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ" ("សំណើ")[1]។ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាបានគាំទ្រញត្តិនេះ ដោយមិនបានបន្ថែមអ្វីទាំងអស់[2]។

២. ដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងអំពីការមិនគោរពវិធានច្បាប់ពីសំណាក់ក្រុម មេធាវីការពារក្ដីលោក ខៀវ សំផន ("មេធាវីការពារក្ដី") ដើម្បីស្នើសុំឱ្យអង្គជំនុំជម្រះ តុលាការកំពូល ("តុលាការកំពូល")៖

១) ណែនាំឱ្យមេធាវីការពារក្ដីដាក់សាជាថ្មីនូវតារាងមូលដ្ឋានសំអាងផ្លូវច្បាប់របស់ខ្លួន រួមជាមួយឯកសារបន្ថែមដែលត្រូវបានតម្រូវទាំងអស់ ស្របតាមមាត្រា ៦ នៃសេចក្ដីណែនាំអនុវត្ត ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ឬទៅតាមក្របខណ្ឌពេលវេលាកំណត់ដោយអង្គជំនុំជម្រះ។

២) ទទួលយកសំណើរបស់សហមេធាវីនាំមុខ ក្នុងដាក់តារាងមូលដ្ឋានសំអាងផ្លូវច្បាប់របស់ខ្លួន ក្នុងរយៈពេល ២៨ ថ្ងៃ ក្រោយពីការដាក់សារណាចម្លើយតបរបស់ខ្លួន[3]។

៣. តាមរយៈចម្លើយតបនេះ មេធាវីការពារក្ដីសូមជំទាស់នឹងសំណើគ្មានមូលដ្ឋានទាំងអស់នេះ។

## **១. សំណើសុំឱ្យណែនាំមេធាវីការពារក្ដីឱ្យដាក់តារាងមូលដ្ឋានសំអាងផ្លូវច្បាប់ថ្មី អមដោយឧបសម្ព័ន្ធចាំបាច់ទាំងអស់**

---

[1] សំណើពាក់ព័ន្ធនឹងការណ៍ដែល ខៀវ សំផន មិនអនុវត្តតាមមាត្រា ៦ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០២០ ឯកសា F56 ("សំណើ")។ សំណើនេះត្រូវបានជូនដំណឹងជាភាសាខ្មែរ និងអង់គ្លេស នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ ហើយដែលមានរយៈពេលសម្រាប់ឆ្លើយតបដល់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០។ សំណើនេះត្រូវបានជូនដំណឹងជាភាសាបារាំងនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការមិនគោរពតាមមាត្រា ៦ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសាររបស់ ខៀវ សំផន ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ឯកសារ F56/1។

[3] សំណើ កថាខណ្ឌ ៩។ សូមមើលផងដែរ កថាខណ្ឌ ២។

៤. បន្ទាប់ពីបានរំលឹកឡើងវិញពីអត្ថបទគតិយុត្តិជាធរមានស្តីពីឯកសារ និងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់[4] ដើមបណ្តឹងរដ្ឋប្បវេណីគូសបញ្ជាក់ពីសារៈសំខាន់នៃបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ពេញលេញអមដោយឧបសម្ព័ន្ធ ជាពិសេសក្នុងករណីសារណាក្រាស់ៗ ដែលមានយោងទៅប្រភពជាច្រើននៅក្រៅ អ.វ.ត.ក[5]។ ដើមបណ្តឹងរដ្ឋប្បវេណីបានកំណត់ចំណុចខ្វះខាតមួយចំនួន នៅក្នុងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់នៃសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីដូចតទៅ៖ ប្រភពមួយចំនួនដែលប្រើនៅក្នុងសារណាបណ្តឹងសាទុក្ខមិនមាននៅក្នុងបញ្ជី ហើយក្នុងចំណោមប្រភពដែលមាននៅក្នុងបញ្ជីទៀតសោត ក៏ភាគច្រើនមិនមានបញ្ជាក់ថា តើប្រភពទាំងនោះត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងហើយឬនៅ ឬថា វាត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធដែរឬទេ។ ដើមបណ្តឹងរដ្ឋប្បវេណីត្អូញត្អែរថាមាន "ការលំបាកខ្លាំង" ក្នុងការស្វែងរកប្រភពទាំងនេះ នៅក្នុងសំណុំរឿង ឬតាមមធ្យោបាយផ្សេងទៀត[6]។

៥. យោងតាមដើមបណ្តឹងរដ្ឋប្បវេណី ទោះបីមេធាវីការពារក្តីបានបង្ហាញ ឬមិនបានបង្ហាញនូវអសុទ្ធចិត្តក្តី ក៏ "ការមិនអនុវត្តតាមមាត្រា ៦ នៃសេចក្តីណែនាំអនុវត្ត មានឥទ្ធិពលទៅលើសមត្ថភាពរបស់ភាគីក្នុងការអនុវត្តតាមតារាងពេលវេលាសម្រាប់ឆ្លើយតបដែលមានស្រាប់"។ អាស្រ័យហេតុនេះហើយបានជាដើមបណ្តឹងរដ្ឋប្បវេណីស្នើតុលាការកំពូលឱ្យណែនាំមេធាវីការពារក្តីឱ្យដាក់ "តារាងមូលដ្ឋានសំអាងផ្លូវច្បាប់ដែលត្រឹមត្រូវ និងពេញលេញ រួមជាមួយឯកសារបន្ថែមទាំងអស់ ដែលត្រូវបានរកឃើញនៅក្នុងបណ្តុំឯកសារច្បាប់នៅ អ.វ.ត.ក ឬនៅក្នុងសំណុំរឿង ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន"[7] ។

៦. មេធាវីការពារក្តីទទួលស្គាល់ដោយមិនបាច់គិតថា បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់នៃសារណាបណ្តឹងសាទុក្ខរបស់ខ្លួន អាចមិនមានលក្ខណៈល្អឥតខ្ចោះនោះទេ ដូចគ្នានឹងខ្លឹមសារនៃសារណាផ្ទាល់ ដែល

---

[4] សំណើ កថាខណ្ឌ ៣, ៤ ដែលយោងទៅវិធាន ៣៩(៦) និង ១០៨(៦) នៃវិធានផ្ទៃក្នុង ព្រមទាំងមាត្រា ៦ នៃសេចក្តីណែនាំអនុវត្ត ជាក់លាក់តែម្តង កថាខណ្ឌ ៦ (១), ៦(៣), ៦(៤)។

[5] សំណើ កថាខណ្ឌ ៥។

[6] សំណើ កថាខណ្ឌ ៦។

[7] សំណើ កថាខណ្ឌ ៧។

ខ្លួនកំពុងតែរៀបចំធ្វើកំណែតម្រូវផ្នែកទម្រង់[8]។ តាំងពីមុនការដាក់ញត្តិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទៅទៀត មេធាវីការពារក្ដីបានកត់សម្គាល់ជាអាទិ៍ថា ខ្លួនមិនបានបញ្ចូលបញ្ជីរៀបរាប់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលខ្លួនបានយោងឡើយ។ អាស្រ័យហេតុនេះ មេធាវីការពារក្ដីបានគ្រោងរៀបចំសេចក្ដីកែតម្រូវនៃបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់របស់ខ្លួន នៅពេលណាខ្លួនបានដាក់សេចក្ដីកែតម្រូវនៃសារណាបណ្ដឹងសាទុក្ខរួចហើយ។

៧. ម៉្យាងវិញទៀត បើទោះជាមេធាវីការពារក្ដីអាចមានកំហុសក៏ដោយចុះ (ដែលខ្លួនមានបំណងកែតម្រូវ) ក៏គេមិនអាចបន្ទោសមេធាវីការពារក្ដីថាមិនបានគោរពតាមវិធានជាធរមាននោះដែរ។ ជាក់ស្ដែង ដើមបណ្ដឹងរដ្ឋប្បវេណី (និងសហព្រះរាជអាជ្ញា) ប្រាកដជាបានភ្លេចវិសោធនកម្មមាត្រា ៦ នៃសេចក្ដីណែនាំអនុវត្តន៍ ដែលត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង និងតុលាការកំពូល។ ចាប់តាំងពីឆ្នាំ២០១១ ភាគីក្នុងសំណុំរឿង ០០២ លែងមានកាតព្វកិច្ចភ្ជាប់ក្នុងឧបសម្ព័ន្ធនូវឯកសារដែលបានលើកឡើងនៅក្នុងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ នៅពេលដែលឯកសារទាំងនេះមាននៅក្នុងស្ថាប័នសាធារណៈរួចស្រេច និងអាចឱ្យគេពិគ្រោះបានយ៉ាងងាយស្រួល៖

> “[អង្គជំនុំជម្រះតុលាការកំពូល] ជូនដំណឹងដល់ភាគីនៃសំណុំរឿង ០០២ ថា ដូចអង្គជំនុំជម្រះសាលាដំបូងដែរ **អង្គជំនុំជម្រះតុលាការកំពូលនឹងអនុញ្ញាតឱ្យភាគីទាំងអស់មិនចាំបាច់ដាក់សេចក្ដីចម្លងនៃបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលបានប្រើប្រាស់ជាឯកសារយោង** ដូចជា ករណីយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ និងអត្ថបទនានានៃលិខិតុបករណ៍អន្តរជាតិល្បីៗ **ដែលមានជាសាធារណៈរួចហើយ ហើយអង្គជំនុំជម្រះតុលាការកំពូល និងគ្រប់ភាគីទាំងអស់អាចទទួលបានយ៉ាងងាយស្រួល**។ ចំពោះឯកសារយោងសំអាងផ្លូវច្បាប់នានាដែលមិនអាចរកបានដោយងាយស្រួលវិញ ភាគីត្រូវដាក់បញ្ជីឯកសារនៅក្នុងតារាងមូលដ្ឋានសំអាងផ្លូវច្បាប់ស្របតាមសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ។ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការយោង ភាគីត្រូវរៀបរាប់បញ្ជីឈ្មោះឯកសារយោងសំអាងផ្លូវច្បាប់ទាំងអស់នៅក្នុងបញ្ជីតារាងមូលដ្ឋានសំអាងផ្លូវច្បាប់”។ (យើងជាអ្នកគូសបញ្ជាក់)[9] ។

---

[8] មេធាវីការពាក្ដីបានប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីអាចដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួនឱ្យទាន់តាមពេលវេលាកំណត់ជាមួយធនធានដែលខ្លួនមាន ដែលតិចជាងអ្វីដែលខ្លួនបានស្នើសុំទៅតុលាការកំពូល និងអង្គភាពគាំពារការការពារក្ដី។ ជាអកុសល មេធាវីការពារក្ដីមិនមានពេលសម្រាប់អានសារណារបស់ខ្លួនឡើងវិញដូចដែលខ្លួនប្រាថ្នាចង់ធ្វើនោះទេ។

[9] អនុស្សរណៈរបស់តុលាការកំពូលដែលមានចំណងជើងថា “វិសោធនកម្មនៃលក្ខខណ្ឌតម្រូវក្នុងការដាក់សេចក្ដីចម្លងនៃបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់” ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០១១ ឯកសារ E116/1/3។ សូមមើលអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “វិសោធនកម្មនៃលក្ខខណ្ឌតម្រូវឱ្យភ្ជាប់សម្ភារៈដែលមានក្នុងបញ្ជីតារាងមូលដ្ឋានផ្លូវច្បាប់ដែល

៨. អនុលោមតាមសេចក្តីសម្រេចទាំងនេះរបស់ចៅក្រម[10] ចាប់តាំងពីឆ្នាំ២០១១ មេធាវីការពារក្តីបានភ្ជាប់ជាមួយសារណារបស់ខ្លួននូវប្រភពណាដែលអង្គជំនុំជម្រះ និងភាគីពិបាករកតែប៉ុណ្ណោះ។ មេធាវីការពារក្តីមិនបានខកខានអនុវត្តបែបនេះឡើយ នៅពេលដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[11]។ រហូតមកដល់ពេលនេះ ការអនុវត្តបែបនេះមិនដែលចោទជាបញ្ហាដល់នរណាម្នាក់ឡើយ ទោះក្នុងករណីសារណាក្រាស់ៗក៏ដោយ។

៩. យោងតាមការលើកឡើងខាងលើ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យបង្គាប់ឱ្យមេធាវីការពារក្តីដាក់ "មូលដ្ឋានសំអាងផ្លូវច្បាប់ដែលត្រឹមត្រូវ និងពេញលេញ" ជាសំណើគ្មានសុពលភាព ពីព្រោះថាមេធាវីការពារក្តីនឹងរៀបចំដាក់សេចក្តីកែតម្រូវនៃបញ្ជីនេះ តាមដែលខ្លួនអាចធ្វើបាន ដោយមេធាវីការពារក្តីនឹងកែតម្រូវអ្វីដែលត្រូវកែតម្រូវ។ ខ្លួននឹងធ្វើកិច្ចការនេះ "ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន" ទៅតាមមធ្យោបាយរបស់ខ្លួនដែលត្រូវបានកាត់បន្ថយយ៉ាងខ្លាំងដោយអង្គភាពគាំពារការការពារក្តី បន្ទាប់ពីសារណាបណ្តឹងសាទុក្ខត្រូវបានដាក់រួចហើយ[12]។ យ៉ាងណាក៏ដោយ ចាំបាច់ណាស់ដែលត្រូវបញ្ជាក់ថា ឯកសារមូលដ្ឋានសម្អាងផ្លូវច្បាប់ទាំងអស់ត្រូវបានយោងយ៉ាងលម្អិតនៅក្នុងសារណា ទៅតាមទីតាំងនៃអំណះអំណាងដែលបានយកវាមកសម្អាង ដូច្នេះវាមិនបានរារាំងដល់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើការរៀបចំចម្លើយតបរបស់ពួកគាត់ឡើយ។

១០. ចំពោះសំណើសុំឱ្យបង្គាប់ឱ្យមេធាវីការពារក្តីភ្ជាប់ "ប្រភព និងឧបសម្ព័ន្ធទាំងអស់ដែលមិនមាននៅក្នុងបណ្ណាល័យឯកសារច្បាប់នៅ អ.វ.ត.ក ឬនៅក្នុងសំណុំរឿង" សំណើនេះមិនមានមូលដ្ឋានទេ បើយោង

---

មានជាសាធារណៈរួចហើយ និងអាចរកបានពីភាគីទាំងអស់" ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ឯកសារ E72។

[10] សំណើ កថាខណ្ឌ ៣ ដែលយោងទៅវិធាន ៣៩(៦) នៃវិធានផ្ទៃក្នុង៖ "ឯកសារ [...] ដែលដាក់មកអង្គជំនុំជម្រះវិសាមញ្ញ ត្រូវដាក់ជូនក្រឡាបញ្ជី [...] ស្របតាមច្បាប់កម្ពុជាជាធរមាន វិធានផ្ទៃក្នុងនេះ សេចក្តីណែនាំអនុវត្ត និងសេចក្តីសម្រេចរបស់ចៅក្រម **តាមករណីសមស្រប**" (យើងជាអ្នកគូសបញ្ជាក់)។

[11] ឧបសម្ព័ន្ធ F54.1.11 ដល់ F54.1.51 (ក្នុងករណីដែលមេធាវីភ្លេចភ្ជាប់មូលដ្ឋានសំអាងផ្លូវច្បាប់ដែលពិបាករក មេធាវីការពារក្តីនឹងភ្ជាប់មកជាមួយនៅពេលដាក់កំណែបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់)។ ម្យ៉ាងទៀត សម្រាប់មូលដ្ឋានសម្អាងផ្លូវច្បាប់ដែលបានមកពីប្រភពសាធារណៈ ហើយដែលចៅក្រម និងភាគីនៃសំណុំរឿងអាចរកមើលបានដោយងាយស្រួល ជារឿយៗមេធាវីការពារក្តីបានបញ្ជាក់ពីទីកន្លែងដែលអាចចូលទៅមើលបាន (វេបសាយ បណ្ណាល័យរបស់អ.វ.ត.ក. . .)។

[12] ប្រធានអង្គភាពគាំពារការការពារក្តីបានប៉ាន់ប្រមាណថាចាប់ពីពេលដាក់សារណាបណ្តឹងសាទុក្ខហើយ មេធាវីត្រូវធ្វើការតែកន្លះថ្ងៃ ក្នុងមួយថ្ងៃ (៥០%) ហើយមានអ្នកជំនួយការតែ ២ នាក់តែប៉ុណ្ណោះ។

តាមសេចក្តីសម្រេចរបស់តុលាការកំពូលដែលបានធ្វើវិសោធនកម្មលើមាត្រា ៦ នៃសេចក្តីណែនាំអនុវត្តន៍ ដោយលើកលែងភាគីពីកាតាព្វកិច្ចនេះ។

១១. ដូច្នេះ ផ្នែកទីមួយនៃសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែបដិសេធចោល។ ផ្នែកទីពីរក៏ត្រូវបដិសេធចោលដែរ។

## ២. <u>សំណើសុំពន្យារពេលកំណត់សម្រាប់ការដាក់បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី</u>

១១. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ខ្លួនត្រូវការពេលវេលាបន្ថែមយ៉ាងតិច ២៨ ថ្ងៃ ដើម្បីដាក់មូលដ្ឋានសំអាងផ្លូវច្បាប់ និងឧបសម្ព័ន្ធនៃសារណាជាចម្លើយតបនៅថ្ងៃខាងមុខរបស់ខ្លួន "ដើម្បីបំពេញពេលវេលាដែលបានបាត់បង និងផលប្រយោជន៍ពីគុណសម្បត្តិដូចគ្នាដែលមេធាវីការពារក្តីទទួលបាន"[13]។

១២. មេធាវីការពារក្តីមិនបានទទួលអត្ថប្រយោជន៍ណាមួយទាល់តែសោះ។ ការលើកលែងចៅក្រមមិនឱ្យភ្ជាប់ប្រភពឯកសារយោងទាំងអស់ ត្រូវអនុវត្តចំពោះភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវការពេលវេលាបន្ថែមដើម្បីធ្វើកិច្ចការនេះទេ។

១៣. លើសពីនេះទៀត មិនមាន "ពេលវេលាខាតបង់ណាមួយ" ដែលត្រូវ "ទូទាត់សង" ឡើយ។ ចៅក្រមសម្រេចធ្វើវិសោធនកម្មមាត្រា ៦ នៃសេចក្តីណែនាំអនុវត្តន៍ ដោយសារតែពួកគាត់បានពិចារណាថា ភាគី និងចៅក្រមផ្ទាល់ នឹងមិនទទួលរងនូវផលប៉ះពាល់ណាមួយឡើយ ក្នុងការស្វែងរកប្រភពឯកសារនៅក្នុងស្ថាប័នសាធារណៈ និងអាចចូលពិគ្រោះបានយ៉ាងងាយស្រួល។ ម៉្យាងទៀត វាជាការងារធម្មតានៅក្នុងតុលាការផ្សេងៗទៀត ទោះក្នុងករណីឆ្លើយតបចំពោះភាគីផ្សេងៗក្តី ឬក្នុងករណីប្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចក្តី (រាប់បញ្ចូលទាំងសាលក្រមដ៏ក្រាស់ៗផងដែរ)។ ជាងនេះទៅទៀត ទាំងដើមបណ្តឹងរដ្ឋប្បវេណី ទាំងសហព្រះរាជអាជ្ញា មិនដែលតវ៉ាអំពីការដែលត្រូវបំពេញការងារនេះទេ រួមទាំងនៅពេលក្រោយការដាក់សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារ

[13] សំណើ កថាខណ្ឌ ៨។

ក្ដីក្នុងសំណុំរឿង ០០២/០១ ឬនៅក្រោយពេលដាក់សារណាសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល នៅក្នុងសំណុំរឿង ០០២/០២ ដែលត្រូវបានដាក់ ដោយអនុលោមតាមការលើកលែងថៅក្រមមិនឱ្យដាក់ប្រភពឯកសារយោង បើទោះបីកាលនោះ ជាសមមាត្រ ពួកគេមានពេលវេលាឆ្លើយតបខ្លីជាងពេលឆ្លើយតបនឹងសារណាបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ នេះ ទៅទៀត។

១៤. លើសពីនេះទៀត មេធាវីការពារក្ដីពិបាកនឹងមើលឃើញពីផលប៉ះពាល់ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្ដឹងរដ្ឋប្បវេណី ទៅលើសមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតបនៅក្នុងពេលវេលាដែលបានកំណត់សម្រាប់ពួកគេ[14] ពីព្រោះថាពេលវេលាកំណត់នេះមិនទាន់បានចាប់ផ្ដើមរាប់នៅឡើយ[15]។

១៥. ចុងបញ្ចប់ គួរគប្បីកត់សម្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីនៅឆ្ងាយពីការទទួលរងផលប៉ះពាល់ ព្រមទាំងទទួលបានពេលវេលា និងមធ្យោបាយជាច្រើនសម្រាប់ការឆ្លើយតបរបស់ពួកគេ។ ពួកគេអាចដឹងអំពីសម្អាងហេតុនៃសាលក្រមចាប់តាំងពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩[16] ក៏ដូចជាសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ចាប់តាំងពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩[17]។ ពួកគេទទួលបានការជូនដំណឹងអំពីសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ជាភាសាបារាំង នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០២០[18]។ មិនដល់មួយម៉ោងក្រោយមកផង ដើម្បីជួយសម្រួលដល់ការងាររបស់ពួកគេ មេធាវីការពារក្ដីបានផ្ញើទៅពួកគេ (និងទៅសហព្រះរាជអាជ្ញា) នូវសំណៅ WORD នៃ

---

[14] សំណើ កថាខណ្ឌ ៥-៨, ជាពិសេស កថាខណ្ឌ ៧។

[15] មាត្រា ៨(៥) នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារចែងថា រយៈពេលកំណត់ចាប់ផ្ដើមរាប់ចាប់ពីពេលមានការជូនដំណឹងជាភាសាខ្មែរ និងជាភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក។ មិនទាន់មានការជូនដំណឹងអំពីសំណៅបកប្រែជាភាសាខ្មែរនៃសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីនៅឡើយទេ ក្នុងពេលបច្ចុប្បន្ននេះ។

[16] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ។ ឯកសារនេះត្រូវបានជូនដំណឹងនៅថ្ងៃទី ២៨ ខែមិនា ឆ្នាំ២០១៩។

[17] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់លោក ខៀវ សំផន (០០២/០២) ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ E465/4/1 ឯកសារនេះត្រូវបានជូនដំណឹងក្នុងថ្ងៃតែមួយជាភាសាបារាំង និងភាសាខ្មែរ និងជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ ។

[18] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ F54។ សំណៅជាភាសាបារាំងនៃឯកសារនេះ ត្រូវបានជូនដំណឹងនៅថ្ងៃបន្ទាប់វេលាម៉ោង ១០ និង ៥៤នាទី និងជាភាសាអង់គ្លេសនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០។

សារណារបស់ខ្លួន[19]។ ប្រហែលជាពីរខែក្រោយមក[20] ពួកគេបានទទួលសារណាបកប្រែជាភាសាអង់គ្លេស មុនពេលបានទទួលសំណៅជាភាសាខ្មែរទៅទៀត (ចំណុចចាប់ផ្តើមរាប់ពេលវេលាសម្រាប់ឆ្លើយតប) ដែលជាករណីលើកលែងយ៉ាងច្បាស់។ ពួកគេត្រូវបានអនុញ្ញាតឱ្យដាក់ការឆ្លើយតបរបស់ពួកគេ (ទាក់ទងតែនឹងមូលដ្ឋាននៃបណ្តឹងសាទុក្ខ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី) តែមួយភាសាសិនសម្រាប់ដំណាក់កាលដំបូង ក្នុងរយៈពេល ៤០ ថ្ងៃ បន្ទាប់ពីការជូនដំណឹងជាភាសាខ្មែរនៃការឆ្លើយតបរបស់សហព្រះរាជអាជ្ញា[21]។ ការឆ្លើយតបនេះទៀតសោត ត្រូវតែដាក់តែមួយភាសាប៉ុណ្ណោះ ក្នុងរយៈពេល ១២០ ថ្ងៃ បន្ទាប់ពីការជូនដំណឹង អំពីសារណាបណ្តឹងសាទុក្ខជាភាសាខ្មែររបស់មេធាវីការពារក្តី (ដែលការជូនដំណឹងនេះនៅតែមិនទាន់បានធ្វើឡើងនៅឡើយ)[22]។ ដូច្នេះ អាស្រ័យលើពេលវេលាកំណត់សម្រាប់ការបកប្រែ ដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនត្រូវដាក់ការឆ្លើយតបរបស់ពួកគេ មុនដំណាច់ឆ្នាំ២០២០ / ដើមឆ្នាំ២០២១ នោះឡើយ។

១៦. ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាគ្រប់គ្រាន់ដើម្បី "ទូទាត់សង" ពេលវេលាដែលចំណាយក្នុងការស្វែងរកប្រភពរបស់ស្ថាប័នសាធារណៈ និងអាចចូលពិគ្រោះយ៉ាងងាយស្រួល បន្ថែមលើការលើកលែងមិនចាំបាច់ភ្ជាប់ប្រភពរបស់ពួកគេ។ សំណើសុំពន្យារពេលរបស់ពួកគេ មិនមានមូលដ្ឋានទេ។

---

[19] សារអ៊ីម៉ែលរបស់មេធាវីការពារក្តី ផ្ញើទៅសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០២០ នៅម៉ោង ១១ និង ៥៣ នាទី។

[20] សូមមើល ខាងលើ កំណត់ត្រាជើងទំព័រ ១៨។

[21] សេចក្តីសម្រេចលើសំណើពាក់ព័ន្ធនឹងសារណាតបរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ F52/1 កថាខណ្ឌ ១២-១៣, ៣០។

[22] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ F49 កថាខណ្ឌ ៣៦។ តុលាការកំពូលក៏បានយល់ព្រមផ្តល់ចំនួនទំព័របន្ថែមទៅដល់សហព្រះរាជអាជ្ញាចំនួន ១៤៥ ទំព័រ សម្រាប់សារណាតបរបស់ខ្លួន ដែលជាមូលហេតុធ្វើឱ្យបន្ថែមពេលវេលាបកប្រែជាភាសាខ្មែរ ហើយដូច្នេះក៏ត្រូវពន្យារពេលដើម្បីចាប់រាប់រយៈពេលសម្រាប់សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ៖ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមទំព័រសារណាតបទៅនឹងសារណាបណ្តឹងសារទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ឯកសារ F55/3 កថាខណ្ឌ ២៦។

១៧. សរុបសេចក្ដីមក សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ដែលគាំទ្រដោយសហព្រះរាជអាជ្ញា សុទ្ធតែគ្មានមូលដ្ឋាន ដូច្នេះ ត្រូវតែបដិសេធចោលទាំងអស់។

១៨. **អាស្រ័យហេតុនេះ** មេធាវីការពារក្ដីស្នើសុំតុលាការកំពូលមេត្តា**បដិសេធចោល**សំណើនេះ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |